# ស្ថានីយផូស៊ីលសត្វសមុទ្រ ភ្នំជញ្ជាំង

ភ្នំជញ្ជាំងជាស្ថានីយ៍ផូស៊ីលសត្វសមុទ្របុរាណ មានទីតាំងស្ថិតនៅសង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ ភ្នំនេះស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦ ហួសសាលាខេត្តបន្ទាយមានជ័យ ឆ្ពោះទៅកាន់ប៉ោយប៉ែត នៅខាងស្តាំដៃចូលតាមក្លោងទ្វារវត្តភ្នំជញ្ជាំង (រូបលេខ១)។ ក្នុងឆ្នាំ២០១៩ក្រុមការងារសិក្សាផូស៊ីលរបស់ក្រសួងបរិស្ថាន បានចុះពិនិត្យ និងសិក្សាបឋម។ ក្រោយមកទៀត ភ្នំជញ្ជាំងនេះត្រូវបានរាជរដ្ឋាភិបាលដាក់ជាតំបន់បេតិកភណ្ឌធម្មជាតិភ្នំជញ្ជាំង ដោយមានអនុក្រឹតលេខ៦៩ អនក្រ.បក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២០ ដែលមានទំហំដី ១៩ហិចតា។

ភ្នំជញ្ជាំងជាប្រភេទភ្នំថ្មកំបោរ ត្រូវបានកំណត់អាយុកាលក្នុងស័កទី១ សម័យ Permian (២៥១-២៩៩លានឆ្នាំ)។[១] ភ្នំជញ្ជាំងមានលក្ខណៈជាផ្ទាំងថ្មកំបោរធំៗដូចជញ្ជាំង ដែលមានការវត្តមួយនៅទីតាំងនោះផងដែរ។ នៅផ្នែកខាងក្រោយនៃព្រះវិហារមានផ្ទាំងថ្មធំៗ គឺកើតឡើងដោយសារកំណកកំបោរដែលបានពីសារធាតុកំបោរនៃពពួកសត្វសមុទ្រ។ អតីតកាលដែលធ្លាប់ជាសមុទ្រកាលពីរាប់លានឆ្នាំមុន កំណកបានកកយ៉ាងក្រាស់ជាបន្តបន្ទាប់ ដែលអាចបង្កើតបានជាផ្ទាំងថ្មយ៉ាងក្រាស់ ដែលមានភស្តុតាងសត្វសមុទ្រមួយចំនួនកប់នៅក្នុងនោះ។ ការសិក្សានៅជាពត៌មានបឋមនៅឡើយ និងបានរកឃើញប្រភេទសផូស៊ីលសត្វសមុទ្រមួយចំនួនដូចជា៖

១. ពពួកគ្រីណូអ៊ីត Crinoid (Class Crinodea) ដែលក្រុមនេះស្ថិតនៅក្បែរពពួកផ្កាយសមុទ្រ ( Class Ophiuroidea ) និងពួកកាំប្រម៉ាសមុទ្រ ( Class Cchinoidea) យើងក៏ធ្លាប់បានចុះផ្សាយលើកមុនផងដែរក្នុងគេហទំព័រ AMS អរិយធម៌ខ្មែរ។[២] ពពួកសត្វគ្រីណូអ៊ីត ដែលយើងបានឃើញនៅភ្នំជញ្ជាំងនេះ ត្រូវបានកប់ចូលក្នុងសាច់ថ្ម។ មានន័យថាពពួកនេះវាបានកើតមុនថ្មកំបោរតាំងពីពេលថ្មកំបោរនៅជាដីនៅឡើយ។ សំខាន់ត្រង់ថាកំណកនៃពពួកគ្រីណូអ៊ីតនេះ មានចំនួនច្រើនលើសលប់ ដែលកកបង្កើតបានជាថ្មភ្នំយ៉ាងក្រាស់

[១] General Department of Mineral Resource,2010, Geological Map of Cambodia

[២] https://ams.com.kh/khmercivilization/detail/7547

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

(រូបលេខ២២)។ ពួកសត្វគ្រីណូអ៊ីតនេះបានបន្តរស់មកដល់ពេលបច្ចុប្បន្ន គ្រាន់តែពូជន៍ផ្សេងគ្នាតែប៉ុណ្ណោះក្នុងប្រទេសកម្ពុជាក៏នៅមានផងដែរ។ [៣]

២- ផ្កាថ្ម ដែលរកឃើញនៅភ្នំបាក់នេះ ស្ថិតក្នុងសាខា Filum Cnidaria, ចំណាត់ថ្នាក់ Class Scleractinia[៤] មានលក្ខណៈប្រហាក់ប្រហែលនិងផ្កាថ្មមួយចំនួនដែលមានមកដល់ពេលបច្ចុប្បន្ន(រូបលេខ២៣)។

៣-ខ្យង យើងក៏បានរកឃើញប្រភេទខ្យងខ្វះ ដែលមាននៅតំបន់នោះផងដែរ គឺនៅចំនុចជើងភ្នំជញ្ជាំងបន្តទៅភ្នំបាក់(រូបលេខ២៤)។ ខ្យងនោះ ស្ថិតនៅក្នុងសាខា នៃ Filum Mollusca ក្នុងចំណាត់ថ្នាក់ Class Gastropoda[៥] និងមិនទាន់កំណត់ឈ្មោះវាបាននៅឡើយ។ នេះក៏អាចបញ្ជាប់អំពីវត្តមានដ៏ចំណាស់នៃប្រភេទខ្យងសមុទ្រ មួយប្រភេទនេះលើតំបន់នៃភ្នំជញ្ជាំងផងដែរ។

៤-អាម៉ូនីត ជាប្រភេទសត្វដែលមានលក្ខណៈប្រហាក់ប្រហែលខ្យង យើងមិនទាន់មានពាក្យប្រើប្រាស់ជាភាសាខ្មែរនោះទេ។ ពពួកនេះក៏ស្ថិតនៅក្នុង សាខា Filum Mollusca ជាមួយពពួកខ្យង និងលាសផងដែរ គ្រាន់តែខុសចំណាត់ថ្នាក់តែប៉ុន្នោះ ដែលហៅថា Class Cephalopoda។ អាម៉ូនីតដែលបានរកឃើញនៅភ្នំបាក់នេះ រកឃើញនៅផ្នែកខាងជើង នៃជើងភ្នំជញ្ជាំង មានទំហំប្រមាណ៤ស.ម និងមានស្នាមកន្ទួកដុំៗនៅលើសំបក មានទម្រង់ប្រហាក់ប្រហែលខ្យងតែមានរាងសំប៉ែត(រូបលេខ២៥)។

៥- អាម៉ូនីតមួយប្រភេទទៀត ដែលមានរូបរាងផ្សេងមានស្នាមឆ្នូតៗទទឹងខ្លួន មានទំហំប្រមាណ៨ស.ម ស្ថិតក្នុង Filum Mollusca និង Class Cephalopoda(រូបលេខ២៦) ។

ចំនុចទាំងឡាយដែលបានបង្ហាញខាងលើជាផ្នែកមួយនៃពត៌មានបឋម ដែលបានរកឃើញក្នុងការសិក្សាស្រាវជ្រាវអំពីផូស៊ីលនៅកម្ពុជា។ ភ្នំជញ្ជាំងជាស្ថានីយផូស៊ីលសត្វសមុទ្រ ដែលមានតម្លៃសម្រាប់ការសិក្សាស្រាវជ្រាវជីវៈចម្រុះសម័យបុរាណ សម្រាប់ផ្នែក

---

[៣] https://ams.com.kh/khmercivilization/detail/7547

[៤] https://www.digitalatlasofancientlife.org

[៥] https://www.digitalatlasofancientlife.org

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

វិទ្យាសាស្ត្រ និងការអប់រំ និងការវិវត្តនៃប្រវត្តិសាស្ត្រធម្មជាតិរបស់ប្រទេសកម្ពុជាតាំងស័ក ទី១ Paleozoic ក្នុងសម័យ Permian (២៥១-២៩៩លានឆ្នាំ)។

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១៖ វត្តភ្នំជញ្ជាំង និងផ្ទាំងថ្មធំនៅខាងក្រោយ



រូបលេខ២៖ កំណកផូស៊ីល ត្រីឡូអ៊ីត ក្នុងថ្មកំបោរ

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១៣៖ ផ្កាថ្ម



រូបលេខ១៤៖ ខ្យង

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៥៖ អាម៉ូនីត



រូបលេខ២៦៖ អាម៉ូនីត

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ